ខ្ញុំបាទសូមលោកមេបាអនុញ្ញាត ត្បិតថ្ងៃក៏កៀក ខែក៏ជិត ខ្ញុំបាទគិតគួរសង់ផ្ទះរះ សម្បែងមិនទាន់ ខ្ញុំបាទសូមប្រគល់ប្រាក់ចំនួន....................ជំនួសថ្លៃផ្ទះ ហើយសុំផ្ទះលោកមេបារៀបវិវាហមង្គលការ ។ សូម ប្រសាសន៍ សូមទានជ្រាប ។

**-មេបា** : ចុះឥឡូវនេះ ប្រាក់ខាន់ស្លានៅឯណា ?

**-ចៅមហា** : តើលោកមេបាបានទទួលប្រាក់ខាន់ស្លាចំនួនប៉ុន្មានហើយ ពីថ្ងៃមុន ?

**-មេបា** : យើងបានទទួល ៣.០០០កហាបណៈហើយ តើប្រាក់ទាំងបីពាន់កហាបណៈនេះលោកចាន់ទុកជាប្រាក់ខាន់ស្លា ឬសម្រាប់ហូបពិសាក្នុងកិច្ចទម្រង់ការ ។

**-ចៅមហា** : ប្រាក់ចំនួន ៣.០០០កហាបណៈនេះ ១.៥០០សម្រាប់ហូបពិសា និង ១.៥០០ទៀតសម្រាប់ទុកជាប្រាក់ ខាន់ស្លា ។

**-មេបា** : បានទទួលដឹងឮ......................

**-ចៅមហា** : សូមទានជ្រាបជំរាបអស់លោកមេបា កាលឃ្លាមុនចៅមហាខ្ញុំបាទបានប្រគល់ប្រាក់ជូនលោកមេបា លោកក៏ព្រមទទួល ឃ្លានេះចៅមហាខ្ញុំបាទ សុំចូលតាមច្រក សុំដករនុក សុំកំពង់ដងទឹក សុំដីសង់រោងខាន់ស្លា សុំទាំងដីធ្វើបង្ការ ចង្ក្រានចុងភៅ សុំទាំងផ្លូវបររទេះ ចូលមកដាក់ក្នុងភូមិ សុំព្រៃកាច់អុស ព្រៃដោះទឹកសត្វតូច-ធំ ក្រែងស្រុកភូមិលោកមេបា មានអារក្ស អ្នកតាឯណាពូកែ ។ សូមលោកបង្ហែរឱ្យចៅមហាខ្ញុំបាទផង មហាខ្ញុំបាទសុំដីត្រង់ណាវាលចងគោ ក្រែងលោលោក មេបាមានដំណាំដាំដុះ ដូចជាចេក អំពៅ ត្រាវ ដំឡូង ស្វាយ ខ្នុរ ល្ហុត សេដា ទៀប ម្នូ ស្លា ត្របែក ដូង ក្រែងគោខ្ញុំបាទយិត យោងបេះបោច បាក់មែករហែកធាងមួយពីរ សូមលោកមេបាមេត្តាអនុញ្ញាតដល់ចៅមហាខ្ញុំបាទផង ។ សូមមានប្រសាសន៍ សូមទានជ្រាប ។

**-មេបា** : បានទទួលសំណូមពរ និង អនុញ្ញាតតាមការសុំ......

**-ចៅមហា** : សូមទានជ្រាបជំរាបអស់លោកមេបា កាលឃ្លាមុនមហាខ្ញុំបាទ សុំដីសង់រោងខាន់ស្លា លោកក៏ព្រមអនុញ្ញាត ឥឡូវចៅមហាខ្ញុំបាទ ក្នុងឃ្លានេះទៀត សុំលើកជណ្តើរចាស់ ផ្លាស់ជណ្តើរថ្មី សុំបើកជញ្ជាំងចងភ្ជាក់ដៃ សូមលោកមេបាចាត់អាជ្ញាកណ្តាលឱ្យទៅអង្កេតពិនិត្យមើល ក្រែងមានជញ្ជៀនមាស ចិញ្ជៀនប្រាក់ ច្រឡំទុកដាក់ក្នុងថតរបាជញ្ជាំង តាំងពី ល្វែងតាកឆ្នៀងរៀងល្វែងជ័យដល់ល្វែងច័ន្ទ សូមមានប្រសាសន៍ សូមទានជ្រាប ។

**-មេបា** : អនុញ្ញាតតាមសម្ដី

**-ចៅមហា** : ខ្ញុំបាទស្នើលោកមេបាទុកឱ្យហើយ ក្រែងលោកមេបាមិនបានអង្គុយរង់ចាំនៅក្នុងកិច្ចមង្គលការនេះ ចៅ មហាខ្ញុំបាទសូមស្នើរៀបចំពិធីមួយចំនួនដូចជា : កាត់សក់ សូត្រមន្ត សែនក្រុងពាលី សែនចងដៃកូនប្រុស-ស្រី

រៀងផ្លែឈើ ជុំពេលា ជាវខាន់ស្លា ។ល។ លុះដល់ថ្ងៃស្អែក ជាថ្ងៃបរមសុខា ចៅមហាខ្ញុំបាទនឹងសុំនាំផ្កាស្លាជ័យ ម្លូជ័យ និង អ្នកសាមីខ្លួនមក ប្រគល់ជូនលោកមេបាជាកិច្ចបញ្ចប់ទម្រង់ការ ។ សូមមានប្រសាសន៍ សូមទានជ្រាប ។

**-មេបា** : សូមកាត់ចុះ តែសុំឱ្យអែបទៀបខាងជាមួយគ្នា ។

**-ចៅមហា** : ឥឡូវលោកមេបាបានអនុញ្ញាតឱ្យចៅមហាយើងខ្ញុំរៀបចំកាត់សក់បង្កក់សិរីដល់គូស្វាមី ដើម្បី........ (អត្ថន័យ + ពិធីកាត់សក់ + ភ្លេងសារិកាកែវ) ។ និយាយក្រោយពីកាត់សក់រួច បួងសង្រួងរកកន្ត្រៃមាស ក្រាសប្រាក់ ។ល។

## ( រៀបចំពិធីកាត់សក់ បង្កក់សិរី )

ទទួលភ្ញៀវកិត្តិយសពិសាភោជនាអាហារ (ពេលរសៀល)

**-ចៅមហា** : និយាយពាក្យក្រុងពាលី (ម៉ោង៤) ពិធីក្រុងពាលី ។

**-មេបា** : សូមលោកចៅមហារៀបចំកិច្ចសែនក្រុងពាលីនៅខាងត្បូងល្វែងចន្ទ ផ្ទះលោកមេបា

**-ចៅមហា** : សូមលោកអ្នកភ្លេងលេងបទកងសោយ អញ្ជើញក្រុងពាលី ។

**(ភ្លេងលេង)**

**-ចៅមហា** : (និយាយ) សុំរៀងផ្លែឈើ ឬ បុកលក្ខណ៍ មានភ្លេង៤បទ រកប្រុស៤ ស្រី៥ រួមមាន :

-ប្រុសឈ្មោះ : ជ័យ , សួស , មាន , បាន

-ស្រីឈ្មោះ : កែវ , កង , មាស , ប្រាក់ , ពិទូរ្យសូរ្យកាន្ត

**-ចៅមហា** : (និយាយ) សូមទានជ្រាប ជំរាបអស់លោកមេបា ជុំពេលា និងជាវខាន់ស្លា លោកមេបាយកណាជាមុន ទុកណាជាក្រោយ សូមប្រសាសន៍ សូមទានជ្រាប ។

**-មេបា** : ទំនៀមទម្លាប់ស្រុកមេបា យកជុំពេលាជាមុន ។

**-ចៅមហា** : សូមទានជ្រាបជំរាបអស់លោកមេបា ពេលា សព្វសំរិទ្ធិវង្គ ពេញវង់ ជាន់ឆាយពេលណាមួយ សូមប្រ សាសន៍ សូមទានជ្រាប ។

**-មេបា** : ពេលាមានអំពីលោកព្រះអាចារ្យ ។

**-ចៅមហា** : សូមទានជ្រាបជំរាប់លោកមេបា....................ដល់កូនប្រុស-ស្រី ហេតុដូច្នេះសូមលោកបំពេញពេលា ជាសាធុ ។

**-មេបា** : សាធុ ៣ដង

**-ចៅមហា** : (**និយាយពីរជាវខាន់ស្លា**)

**-មេបា** : សុំយកភាសាលោកអ្នកភ្លេង

**ចៅមហា** : បើអញ្ជឹង សូមគោរពអញ្ជើញលោកអ្នកភ្លេងលេងបទជាវខាន់ស្លា (ជាចំរៀងចាប៉ីដងវែងក៏បាន ឬចំរៀងភ្លេងការក៏បាន) ដើម្បីជូនលោកមេបា ។

(ជ្រងដើមបទមុន.........ចាប៉ីចាប់ផ្តើម)

ជ្រងអើយជ្រងនាយ ជ្រងអ្នកបន្ទាយ ជជាយឡើងគាល់ អស់លោកមេបា លោកអង្គុយរៀងរាល់ ជជាយឡើងគាល់ សុំជាវខាន់ស្លា ។

**ច្រៀងថ្លៃ** (ចប់) អ្នកភ្លេងសួរលោកមេបា តើកូនបង កូនកណ្តាល ឬកូនពៅ លោកកាន់តាមរាជស័ក្តិ , ឧត្តុង្គស័ក្តិ, បុរាណស័ក្តិ ឬ ភពស័ក្តិ ? លោកកាត់ប៉ុន្មានតម្លឹង ? ប៉ុន្មានស្លឹង ? ប៉ុន្មានបាត ?

**មេបា** : កូនខ្ញុំបាទជាកូនច្បង ខ្ញុំសូមកាត់តាមបុរាណស័ក្តិ , កាត់១៩ដំឡឹង ៤ស្លឹង ២បាត ប្រាក់ត្រាប្រាសាទ តាគង់តាគាំដើមដៃ ។

**(សម្រាកពេលយប់)**

## លុះដល់ព្រឹកឡើងថ្ងៃបន្ទើយមង្គលការ

**អាចារ្យ** : រៀបបង្វិលពពិល (ទៀបភ្លឺ) (រួចឱ្យអ្នកភ្លេងលេងបទនាគព័ន្ធ ផាត់ជាយ)

-ហូតដាវ , បើកទៀប , បាយខុន , អាចារ្យឱ្យពរ..........................

-ព្រះថោងតោងស្បៃ.......................................................

-សាកន្ទេស ចងសំពោង.......................................................

## ពរពេលព្រឹកជាពរបញ្ចប់មង្គលការ

អស់ឱតេជៈព្រះអាទិត្យរៀងរះពីបូពិទិសា សូមឱ្យអ្នក និងនាងជាគូភិរិយាបានមូលមិត្តសុខជាឧត្តម **នមោសេដ្ឋោ នមស្ការោ** ក្រួញក្រាបបង្គំដល់ព្រះចមភព ជាម្លប់ឧត្តមព្រះអង្គជាធំលើសភពផែនដី ។

-អស់ឱតេជះខ្ញុំក្រាបសំពះទន់ទាំងសិរសី សុំពរអំពីសម្តេចព្រះជិនស្រី ឱ្យអ្នកការថ្មីជាប្តីប្រពន្ធ សូមឈ្នះចង្រៃ ប្រាសចាកទុក្ខភ័យ ប្រសើរលើសលន់ ។ ឱព្រះគុណថ្លៃមានគុណលើសជន សូមព្រះគុណធ្ងន់មេត្តាឱ្យពរ ពឹងគុណព្រះធម៌ ប្រសើរបវរឈ្នះបាបខ្មារខ្មៅ ជំងឺដង្កាត់កុំបីរីរវ ព្រះធម៌សាទរ ឱ្យពរឈ្នះភ័យ ។ ពឹងគុណព្រះសង្ឃ ធ្វើចិត្តឱ្យត្រង់ ប្រតិបត្តិថ្លាថ្លៃ សង្ឃជាស្រែបុណ្យ ជនដឹងសព្វថ្ងៃ ព្រះសង្ឃឱ្យជ័យ ឱ្យពរឈ្នះរោគ ។ គុណកែវទាំងបី សូមឈ្នះចង្រៃ ប្រាសចាកទុក្ខសោក សុខក្នុងលោកិយ សុខដល់បរមលោក ចូលអ្នកទាំងពីរចាំយក ជឿជាក់ដាក់ក្នុងប្រាណ ចៅមហាខ្ញុំបាទឱ្យពរ ចូលអ្នកមានទ្រព្យគ្រប់ប្រការ មានគោក្របី តុ ទូ កៅអី ម៉ូតូហុងដា សឹងមានជាទ្រព្យ ឧត្តមចូលមកជួបជុំចតទុកពេញត្រៀបត្រា ។

-នាងប្រតិបត្តិប្តី ប្រៀបដូចជាស្រីបវរកញ្ញា បំរើព្រះឥន្ទជាស្តេចទេវតា នៅត្រើយត្រីង្សា ពិភពសួគ៌នាយ ។ នាងស្រឡាញ់ប្តីធ្វើចិត្តឱ្យស្លូត កុំបីភរភូត ចិត្តកុំវាយមាយ នាងប្រតិបត្តិប្តី ដូចបាវនិងនាយ ។

ឱនលំទោនកាយថ្វាយវរវន្ទា នាងស្រឡាញ់ប្ដីរៀងម្លូស្លាបារី សព្វគ្រប់វេលា បើនាងចូលដេកខាងឆ្វេងប្ដីជា ឱ្យនាងមានអាយុរយឺនយូរតទៅ នាងអើយមាត្រា ច្បាប់ស្រីនេះណា ក្រណាស់ណាពៅ នាងប្រឹងឱ្យបាន ជាស្ពានដើរទៅ កាន់នាលំនៅពិភពសួគិនាយ ។ កបកើតទ្រព្យបរិបូណ៌ហូរហៀរ ពោរពាសស្ដុកស្ដម្ភ ចូលអ្នកចងចាំទុក ពរនេះទៅមុខឈ្នះទុក្ខរោគា ពរនេះមាំ មួនប្រាំពីប្រការ ព្រះប្រោសទេសនាថាប្រសើរក្រៃ **អាយុវឌ្ឍនោច** ចំរើនពរពាក្យពិតនិយាយ

សូមឱ្យអ្នកទាំងពីរមានអាយុ ១00ឆ្នាំម្នាក់ បានដូចទំនាយទុក្ខទោសរសាយ រលត់គ្មានសល់ ។

**ពលវឌ្ឍកំ** សូមឱ្យអ្នកទាំងពីរ មានកំលាំងប្រណាំងស្មើខ្យល់ ។

**ធនវឌ្ឍនោ** ពរនេះថ្កើងថ្កានរកស៊ីកើតផល កើតភាគសម្បត្តិ ។

**វណ្ណវឌ្ឍនោ** សូមឱ្យមានសប្បុរសប្រផូរផង់ផាត់ ។

**សុខវឌ្ឍនោ** សុខលែងឈឺថ្កាត់ រកទ្រព្យសម្បត្តិសំបូរធូរចាយ ។

**យសស័ក្តិវឌ្ឍនោ** បរិវារមូលមក មូលមិត្តជិតឆ្ងាយ ។

**សិរីវឌ្ឍនោ** សិរីរាង្គកាយ មាសប្រាស់ទាំងឡាយសំបូរហូរចូល ។

មានទ្រព្យមិនខ្វះទាំងថ្មីទាំងចាស់ដូចគេប្រមូលមានស្រូវជង្រុក កើបទុកឱ្យមូល ផាមួងព្រៃហូល ស្បៀកពាក់មិនអស់ ។ ម្យ៉ាងទៀតលែងក្រ មានទ្រព្យបវរ ចិត្តល្អរហូត ចិត្តស្លូតត្រង់ស្មោះ ទ្រព្យចាយមិនអស់ ចែកទៅជាទាន ជាទុនតទុក តទៅមុខទុកជាប្រធាន ឱ្យដឹងគុណកិច្ច កុំភ្លេចវិញ្ញាណរកស៊ីឆាប់មានរាល់ថ្ងៃតទៅ ។

ចូរអ្នកទាំងពីរដឹងគុណពីថ្ងៃនេះតទៅ ពិតជាបានសុខជ័យហោង ! សួសហោង..................................................... សុខហោង សុខដូចមាត់ប្រាកដដូចពាក្យថា មែនហោង (មែន) បើមែនមានអ្វីជបន្ទាល់.................(ហ៊ោ) ។

**(ចប់)**

**១~ច្បាប់គោរពមាតាបិតា (បណ្ឌិតអ៊ុំចុង) ២~កិរិយាចិញ្ចឹមជីវិតដោយកំរ (បណ្ឌិតអ៊ុំចុង)**

**៣~ច្បាប់ប្រដៅជនប្រុសស្រី (ភទីក្រមង៉ុយ)៤~កេរ្តិ៍កាលថ្មី (ភទីក្រមង៉ុយ)**

**៥~ច្បាប់ល្បើកថ្មី (ភទីក្រមង៉ុយ)**

**ថតសំលេងដោយលោកគ្រូអាចារ្យ យុត ឃឹម ជាកាសែតម៉ាញេ**

**និង**